# មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0062**

## សម្ភាសន៍ជាមួយឈ្មោះ កែ ឆាប់ ភេទប្រុស អាយុ៦២ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កម្មករកាប់រំលំ

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅភូមិសំរោង ឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

## សព្វថ្ងៃរស់នៅភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ឆាយ ឃុនលី

## ០១:០១:១៤

## ២៧ទំព័រ

ឃុនលី ៖ ជំរាបសួរពូ! ខ្ញុំចង់ដឹងឈ្មោះពូ ត្រកូលអី?

ឆាប់ ៖ ខ្ញុំឈ្មោះ កែ ឆាប់ ។

ឃុនលី ៖ អាយុប៉ុន្មាន?

ឆាប់ ៖ អាយុ៦២ ។

ឃុនលី ៖ នេះនៅភូមិដំបូកវិល?

ឆាប់ ៖ ភូមិដំបូកវិល ។

ឃុនលី ៖ ស្រុកកំណើតនៅណា?

ឆាប់ ៖ ខ្ញុំស្រុកកំណើតនៅភូមិសំរោង ឃុំអូរម្លូ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ។

ឃុនលី ៖ ខ្ញុំចង់ដឹងថាហេតុអីបានពូមកដល់ទីនេះ តាំងពីឆ្នាំ៧៩មក?

ឆាប់ ៖ បាទ! ជំនាន់នឹងខ្ញុំចេញពីផ្ទះមកវាឆ្នាំ និយាយរួមទៅឆ្នាំ៧០ ខ្ញុំចេញបែកម៉ែបែកឪមក សម័យនឹងគេធ្វើបដិវត្ត ។

ឃុនលី ៖ ទៅធ្វើអីគេទៅ?

ឆាប់ ៖ កាលនឹងធ្វើ មុនដំបូងធ្វើបាតុកម្មរំដោះសម្តេចឪ កាលជំនាន់លន់ នល់គាត់ធ្វើរដ្ឋប្រហារសម្តេចនឹង ។

ឃុនលី ៖ ការពិតពូនៅក្រុមនិស្សិត ឬមួយក្រុមអីគេ?

ឆាប់ ៖ ខ្ញុំកាលនឹងនៅសិស្សសាលា ។

ឃុនលី ៖ រៀនបានថ្នាក់ទីប៉ុន្មាន?

ឆាប់ ៖ រៀនថ្នាក់ទី៩កាលនោះ ។

ឈុនលី ៖ ថ្នាក់ទី៩ បើគិតឥឡូវថ្នាក់ទី៨?

ឆាប់ ៖ បាទ!

ឈុនលី ៖ ធ្វើបាតុកម្មនៅណាទៅ?

ឆាប់ ៖ កាលនឹងខ្ញុំធ្វើចេញមក ចេញពីស្រុកមកៗសាលាស្រុកស្ទឹងត្រង់ ចេញពីសាលាស្រុកស្ទឹងត្រង់ទៅ ទៅសាលាស្រុកក្រូចឆ្មារ ។

ឈុនលី ៖ បាតុកម្មយើងទៅដល់សាលាស្រុកម៉ង?

ឆាប់ ៖ បាទ! ទៅដល់តាប៉ាវ មេម៉ត់បានបកមកវិញ ។ កាលនឹងមនុស្សរាប់ម៉ឺន ចេញធ្វើបាតុកម្ម ។

ឈុនលី ៖ ពេលនឹងមានអ្នកណានាំគ្នាធ្វើ?

ឆាប់ ៖ ទេ!អត់ដឹងទេ គ្រូកាលនឹងគេកេណ្ឌតាមគ្រូ តាមភូមិចេះទៅតគ្នា គ្មានគំនិតថាទៅធ្វើស្អី តែក្រោយមកយើងដឹងថាធ្វើបាតុកម្មរំដោះសម្តេចឪ ដឹងតែប៉ុននឹង ។

ឈុនលី ៖ មានមេភូមិមេឃុំគេនាំដែរ?

ឆាប់ ៖ បាទ! មានតើ មានមេខ្យល់ គេថាទៅបាតុកម្មអ្នកណាមិនទៅមិនបាន និយាយរួមមុខទៅ ទៅដល់ភូមិណា ភូមិនឹងចូលរួមទៅរាប់ម៉ឺនសែននាក់ ។

ឈុនលី ៖ បន្ទាប់ពីនឹងមក?

ឆាប់ ៖ បន្ទាប់ពីនឹងមក យើងចូលព្រៃបណ្តោយ ចូលព្រៃតស៊ូ យើងនៅស្រុកអត់បាន ។

ឈុនលី ៖ ម៉េចបានអត់បាន?

ឆាប់ ៖ កាលនឹងគេចោទថាបាតុកម្មនឹងប្រឆាំងជាមួយលន់ នល់ ទាហាននឹងចេះតាមចាប់តាមអី ខ្ញុំចូលព្រៃ ។

ឈុនលី ៖ ចូលព្រៃខ្ទង់ឆ្នាំណា?

ឆាប់ ៖ អាចឆ្នាំ៧០ ។

ឈុនលី ៖ ចូលព្រៃដំបូងពូចូលនៅណា?

ឆាប់ ៖ ខ្ញុំចូលព្រៃម៉ាជួរភូមិកំណើត ។

ឈុនលី ៖ ពេលយើងចូលព្រៃ បានន័យថាយើងធ្វើអីគេ ធ្វើទ័ព?

ឆាប់ ៖ បាទ! កាលនឹងមានអ្នកដឹកនាំអីចូលរួមទៅ ចេះទៅៗ ។

ឈុនលី ៖ នៅស្រុកស្ទឹងត្រង់?

ឆាប់ ៖ បាទ! នៅស្ទឹងត្រង់ ។

ឈុនលី ៖ អានឹងចូលដល់ឃុំអីគេ?

ឆាប់ ៖ កាលនឹងខ្ញុំនៅទាំងចេញពីផ្ទះទៅ គ្រាន់តែព្រៃនៅភូមិខ្ញុំនៅ៣-៤ឆ្នាំ ឆ្នាំ៧៣បានខ្ញុំមកនៅដល់ស្ពឺពព្រេងនេះ ។

ឈុនលី ៖ ស្ពឺពព្រេងនៅណា?

ឆាប់ ៖ ស្ពឺពព្រេងយើងមកពីស្រុកស្ទឹងត្រង់តិចមក កន្លែងវាល ។

ឈុនលី ៖ ខេត្តកំពង់ចាមដដែល?

ឆាប់ ៖ បាទ! ខេត្តកំពង់ដដែល ។

ឈុនលី ៖ ហើយបន្ទាប់មកទៀតម៉េចទៅ?

ឆាប់ ៖ បន្ទាប់មកទៀតមក ឆ្នាំ៧៣គេវ៉ៃកំពង់ចាម ៗ វ៉ៃផ្លូវជាតិលេខ៥ ។

ឈុនលី ៖ ខាងលន់ នល់?

ឆាប់ ៖ អត់ទេ ខ្ញុំខាងខ្មែរក្រហមក្នុងព្រៃ ទ័ពព្រៃ ។

ឈុនលី ៖ គេវ៉ៃនឹង ពូថានៅខេត្តកំពង់ចាមនឹងខាងណាគេវ៉ៃ?

ឆាប់ ៖ ទាហានលន់ នល់នៅក្នុងក្រុង ហើយយើងទ័ពព្រៃនៅក្រៅវ៉ៃគ្នា ។

ឈុនលី ៖ បានន័យថាទាហានខាងក្នុងនឹងគេចូលដល់កំពង់ចាម?

ឆាប់ ៖ ហ្នឹង ទាហានរដ្ឋាភិបាលមួយលន់ នល់ គេនៅខាងក្រុង ហើយខ្មែរក្រហមមិនមកពីព្រៃ ។

ឈុនលី ៖ យើងវ៉ៃចូលក្រុង?

ឆាប់ ៖ ហ្នឹងយើងវ៉ៃដណ្តើមយកក្រុងនឹង ។

ឈុនលី ៖ ហើយម៉េចទៀត?

ឆាប់ ៖ មានប៉ុននឹងដែលចេញពីកំពង់ចាមមក វ៉ៃតាមផ្លូវលេខ៥ មកភ្នំពេញ មកម៉ាផ្លូវព្រែកក្តាម វ៉ៃចូលភ្នំពេញ ។

ឈុនលី ៖ ខ្ទង់ឆ្នាំ៧៥ ពូនៅណា?

ឆាប់ ៖ ៧៥ដាក់នៅភ្នំពេញ ខ្ញុំនៅក្នុងស្ទឹង ។

ឈុនលី ៖ ធ្វើអីគេ?

ឆាប់ ៖ ខ្ញុំធ្វើកម្មករជើងដឹកជញ្ជូនជើងទឹក ។

ឈុនលី ៖ អានឹងនៅក្រោម មានក្រសួងមានអីត្រឹមត្រូវ?

ឆាប់ ៖ មាន ក្រសួងដឹកជញ្ជូនជើងទឹកគេគ្រប់គ្រង ។

ឈុនលី ៖ កាលនឹងអ្នកណាគេអ្នកកាន់ខាងនឹង?

ឆាប់ ៖ ម៉ន ស្អីម៉ន គាត់កាន់ក្រសួងជើងទឹក ។

ឈុនលី ៖ ពូរបៀបដូចកម្មករ?

ឆាប់ ៈ បាទ! យើងនៅក្នុងក្រសួងនឹង គេធ្វើប្រៀបដូចកម្មកររោងចក្រក្រឡឹងកាប៉ាល់ ឬកម្មករបើកបរដឹកជញ្ជូនសម្ភារៈតាមខេត្តអីនឹង ។

ឈុនលី ៈ ចុះដល់ពេល យើងមានជម្លៀសទៅណា ឬមួយក៏ដូរការងារអីអត់?

ឆាប់ ៈ អត់ទេ ខ្ញុំនៅនឹងទាល់តែរត់ចេញពី ខ្ញុំនៅផ្សារព្រែកព្នៅ ។

ឈុនលី ៈ ពេលនៅភ្នំពេញនៅកន្លែងព្រែកព្នៅ?

ឆាប់ ៈ បាទ! នៅរោងចក្រផ្សារព្រែកព្នៅ ។

ឈុនលី ៈ អានឹងគេហៅរោងចក្រអីគេ?

ឆាប់ ៈ រោងចក្រក្រឡឹងកាប៉ាល់នឹង បើជំនាន់នឹងបានស្គាល់ ឥឡូវគេរើចេញអស់ហើយ ។ ព្រោះរោងចក្រនឹងគេទើបតំឡើងជំនាន់សាងសង់កាប៉ាល់ ធ្វើចំណុះ៣៥០តោន ។

ឈុនលី ៈ ដូចការងារពូធ្វើអី?

ឆាប់ ៈ បាទ! យើងដឹងបើកបរ ដឹងបើកបរ ។

ឈុនលី ៈ បើកបរកាប៉ាល់?

ឆាប់ ៈ បាទ! ថាទៅមកសៀមរាបយកមកដាក់ដៃសៀមរាប គេលើកទៅយើងមកវិញមក ចូលដែន ។

ឈុនលី ៈ បើកតាម?

ឆាប់ ៈ តាមដៃទន្លេសាប ជួនកាលឡើងទៅកំពង់ចាម ឡើងទៅក្រចេះ ដឹកស៊ីម៉ង់ ដឹកដែក ដឹកអំបិល ។

ឈុនលី ៈ ការនឹងហូបចុកម៉េចទៅ?

ឆាប់ ៈ ការហូបចុកគេចាត់តាំងជាសហករណ៍ ដោយឡែកយើងឡើងកាប៉ាល់ហូបចុកជាពួក មេកាប៉ាល់៣នាក់ ។ ឲ្យតែចូលពួកគឺចូលសហករណ៍ បាយរួម ។

ឈុនលី ៈ តែហូបគ្រប់គ្រាន់ទេ?

ឆាប់ ៈ កាលនឹងមិនគ្រប់ កាលនឹងហូបបបរ ។

ឈុនលី ៈ ពូការងារនៅកាប៉ាល់ហូបបបរទេ?

ឆាប់ ៈ បាទ! បើយើងបានឡើងកាប៉ាល់នឹងបានសុំគេតាមដែនតាមអីបានហូប ។ ដូចយើងមានស្អីក្រដាស ឬស្អីសហករណ៍គេត្រូវការទៅ យើងដឹកទៅ យើងសុំគេបាន៨-១០កំប៉ុង ឬកន្លះកំប៉ុង ឬម៉ាបាវ ដាក់លើកាប៉ាល់នឹង ។ តែស៊ីបានតែឡើងកាប៉ាល់ៗចូលដៃលាក់ហើយ អត់ឲ្យគេដឹងទេ ។

ឈុនលី ៈ អានឹងដូចយើងលួចគេហូប?

ឆាប់ ៖ បាទ! ដូចលួចគេហូប ។

ឈុនលី ៖ ដល់៧៩?

ឆាប់ ៖ បាទ! ដល់៧៩បានយើងយួនចូលមកយើងរត់មកចេះរហូត ។

ឈុនលី ៖ ហ្នឹងហើយគេប្រាប់យើងថាម៉េច ពេលយើងរត់?

ឆាប់ ៖ ពេលនឹងគេប្រាប់យើងថាយួនឈ្លានពាន ។

ឈុនលី ៖ ហើយគេឲ្យយើងរត់មកខាងនឹង?

ឆាប់ ៖ អឺ!

ឈុនលី ៖ ហើយគេប្រាប់ថាទៅកន្លែងណាមួយ?

ឆាប់ ៖ អត់ទេ កាលនឹងរត់អត់មានទិសដៅទេ ដូចថាចេញពីភ្នំពេញដំណើរមកលិចទៅ ចេះមកតាមគេ ខ្វះមកតាមផ្លូវខ្វះរស់ ។

ឈុនលី ៖ កន្លែងរោងចក្រធំមកទាំងអស់គ្នា?

ឆាប់ ៖ បាទ! មកទាំងអស់គ្នា និយាយរួមកម្មករនៅក្នុងភ្នំពេញមកទាំងអស់ ។

ឈុនលី ៖ ចុះធ្វើម៉េចបានមកដល់ស្រុកម៉ាឡៃនេះ?

ឆាប់ ៖ បាទ! មកៗចេះមកៗយួនដេញចេះមក មិនមកត្រឹមនេះធ្លាយទៅថៃទៅដំរីស្រះកែវ ហើយដល់ក្រោយមកគេប្រមូលយកមកវិញ មកនាំគ្នានៅតាមនឹងទៅ ធ្វើស្មួងធ្វើចំការធ្វើអីវ៉ៃយួនតទៅទៀតទៅ ។

ឈុនលី ៖ ពូមកដល់ម៉ាឡៃនេះខួងឆ្នាំណា?

ឆាប់ ៖ បាទ! ខ្ញុំមកសម័យអ៊ុនតាក់នឹង គេចបារលើកទី១ឆ្នាំប៉ុន្មាន ។

ឈុនលី ៖ ៩៣?

ឆាប់ ៖ បាទ! ប្រហែលជា៩៣ ខ្ញុំគេដឹកជញ្ជូនពីថៃមកនៅតាមនឹង ។

ឈុនលី ៖ ចុះមុននឹងពេលទៅថៃៗឆ្នាំណា?

ឆាប់ ៖ ទៅថៃទៅក្នុងចន្លោះ៧៩ ចាំមើល៧០យើងចូលទៅថៃម្តង ។

ឈុនលី ៖ ៧០ ឬ៨០?

ឆាប់ ៖ អឺ! ៧៩-៨០យើងនៅក្នុងថៃម្តង ។

ឈុនលី ៖ ហេតុអីបានចូលភ្លាមៗ?

ឆាប់ ៖ ហ្នឹងដូចយើងចេះរត់មក យួនមកតាមក្រោយ ចេះរត់ទៅ មិនដែលឃើញយួនរបៀបម៉េចប៉ុនយើងមានកូនមានចៅចេះទៅ ។

ឈុនលី ៖ កាលនឹងពូមានគ្រួសារ?

ឆាប់ ៈ បាទ! ខ្ញុំមានហើយ មានកូនពីររត់មកឆាប់អស់តាមព្រំដែន ។

ឈុនលី ៈ ពេលមកដល់ដំបូងម៉េចទៅ ដូចតំបន់នេះ?

ឆាប់ ៈ បាទ! មកដំបូងវេទនាណាស់ អត់មានអីស៊ីចុក ជីកតែដំឡូង កាប់ចុងសោមចុងផ្អាវស៊ី កាលនឹងអត់ទាន់មានអង្ករទេ អត់ទាន់មានអង្គការណាចុះជួយទេ ។ យើងមកតាមស្រុកបវេលបុកអង្ករត្រៀមមកអស់ត្រឹមណាចាប់ផ្ដើមស៊ីស្លឹកឈើ ជីកដំឡូងជីកអីស៊ីទៅ ។

ឈុនលី ៈ ហូបស្លឹកឈើ?

ឆាប់ ៈ បាទ! ទម្រាំតែខាងគេលើទាក់ទងបានជំនួយយើងចូលមក បានយើងមានអង្ករមានហូបគ្រប់គ្រាន់ ។

ឈុនលី ៈ ចុះមកដំបូង យើងឆ្លងកាត់បវេល ហើយមានទៅណាទៀតមុននឹងមកដល់?

ឆាប់ ៈ ខ្ញុំមកដំបូងមក ខ្ញុំតាមតាមផ្លូវលេខ៥ ចូលនៅសាលាស្រុកបវេក។ទៅប៉ៃលិន។ទៅសំឡូត។បុកទៅខាងផ្ដេរ...ព្រំប្រទល់ខាងឌិវ៉ាល់កោះកុង ។ ដល់ខាងនោះគេស្កាត់វៃខាងមុខ មកចេះវិញចូលម៉ាឡៃ២សារ បាននៅជាប់រាល់ថ្ងៃ ។

ឈុនលី ៈ ពូថាទៅថៃនឹងខ្ទង់៨០ ?

ឆាប់ ៈ បាទ! ទៅថៃ មើល៧៩យើងរត់មក ក្នុងរយៈ៧៩ក៏មានចូលថៃ ដូចយួនចេះមកយើងចេះតែរត់គេចឲ្យផុតម៉ារយៈពេលសិន ដល់ពេលយួនវាបោះទីតាំងទៅនេះទៅនោះវាស្ងប់បុកបានយើងជ្រាតចូលមកវិញ ។

ឈុនលី ៈ ចូលមកវិញឆ្នាំណា?

ឆាប់ ៈ ចូលមកវិញ ។

ឈុនលី ៈ លើកទី១ ?

ឆាប់ ៈ បាទ! លើកទី១ចូលក្នុងឆ្នាំ៨១ ។

ឈុនលី ៈ ហើយដល់ពេលចូលមកវិញ ពូធ្វើអីគេ?

ឆាប់ ៈ ចូលមកវិញ ធ្វើទាហាន ធ្វើកងទ័ពនៅខាងនេះ ។

ឈុនលី ៈ ទ័ពធម្មតា?

ឆាប់ ៈ បាទ! ទ័ពវ៉ៃយួននៅតាមនឹង យើងនៅតាមព្រំដែន ចូលទៅក្នុងទៅវ៉ៃក្នុង ប្រពន្ធកូននៅថៃក្មេង។ស្រី។នៅថៃ ប្រុស។ទៅនៅបវេល យួននៅតាមនឹង ។

ឈុនលី ៈ កាលនឹង ពូដឹងថាតំបន់នឹងមុនដំបូងគេហៅតំបន់អីគេ ខាងម៉ាឡៃនឹង?

ឆាប់ ៈ ទេ! ដូចមិនដឹងយ៉ាងម៉េច។ ដឹងម៉ាឡៃ។ ។

ឈុនលី ៈ ដំបូងគេអត់ទាន់ហៅស្រុក?

ឆាប់ ៖ បាទ! អត់ទាន់ហៅស្រុកទេ គេហៅដូចមានចំនុចគេ កាលនឹងតាមផ្លូវ៥០២ ផ្លូវមកពីនិមិត្ត មកទល់នឹងប៉ៃលិន ដឹងខាង។ ហើយដល់ក្រោយមកឃួនយកផ្លូវ៥០២ បានយើងឆ្ងាយមក នៅតាមមាត់អូរ។

ឈុនលី ៖ ៥០២ផ្លូវណា?

ឆាប់ ៖ ផ្លូវ កាលនឹងផ្លូវជាតិព្រំដែន មានផ្លូវ៥០២ ពីជំនាន់សម្តេចសង្គមរាស្ត្រនិយម ចេញពីនិមិត្ត កូនដំរីមកឆ្ងាយទៅប៉ៃលិន។ តែផ្លូវលំគេទេ តែគេដាក់ផ្លូវជាតិ៥០២។

ឈុនលី ៖ ដូចពូធ្វើទ័ព អ្នកណាគេអ្នកកាន់ខាងទ័ព?

ឆាប់ ៖ អ្នកកាន់ទ័ពបងភាពយើង សុខ ភាព។

ឈុនលី ៖ ហ្នឹងគាត់ធំ?

ឆាប់ ៖ គាត់មេនៅនឹងបណ្តោយ។

ឈុនលី ៖ ចុះដល់ពេលក្រោមៗ?

ឆាប់ ៖ ក្រោមៗតមកខ្វះវរសេនាតូច ខ្វះវរសេនាធំទៅ ខ្វះកងធំ គ្រប់គ្រងចាត់តាំងគ្នាតៗ។

ឈុនលី ៖ ពូនៅក្នុងកងអីគេ?

ឆាប់ ៖ បាទ! ខ្ញុំនៅក្នុងកាលនឹងគេហៅ គេមានពាកងវរសេនាសធំ ១០៩ ១០៨ ១០៧។

ឈុនលី ៖ ចុះអ្នកណាអ្នកកាន់នៅនឹងខ្វះទៅ?

ឆាប់ ៖ បាទ! កាលឈ្មោះនៅ១០៩មានឈ្មោះ តាមួន តាង៉ុន គាត់ធ្វើអភិបាលរងរាល់ថ្ងៃនឹង នឹង ១០៩កាន់វរសេនាធំក្រោមការគ្រប់គ្រងរបស់សុខ ភាព។

ឈុនលី ៖ ពូកាន់ដែរ?

ឆាប់ ៖ បាទ!ខ្ញុំកាលនឹងអត់ទេ ខ្ញុំនៅជាអគ្គភាពចំណុះឲ្យ១០៧ នៅក្រោមការគ្រប់គ្រងរបស់១០៧

ឈុនលី ៖ គេហៅអគ្គភាព?

ឆាប់ ៖ បាទ!

ឈុនលី ៖ យើងធ្វើទ័ពធម្មតារហូត?

ឆាប់ ៖ បាទ! ធ្វើទ័ពធម្មតារហូត។

ឈុនលី ៖ ពូទៅច្បាំងផ្ទាល់?

ឆាប់ ៖ បាទ! គេមានវេណដែលយើងត្រូវទៅចុះទៅ ទៅ៣-៤-៥ខែ ម៉ាឆ្នាំអីឡើងមកម្តង ដូរ វេណគេទៅម្តង។

ឈុនលី ៖ ពេលមកពីថៃ នៅច្បាំង ម៉េចបានទៅវិញ ទៅលើកទី២ដោយសារអីគេ?

ឆាប់ ៖ ដូចថាយើងទៅថ្ងៃហើយមកវិញ ហើយម៉េចបានទៅទៀត?

ឈុនលី  :  ចា៎!

ឆាប់  :  លើកទី២យួនវៃលើកទី២ទៀត  ពីមុនមកគេយកទៅតាមផ្លូវ៥០២ការងារអីយើងនៅបាន ដល់មកឆ្នាំ៨៤  យួនបុកម៉ាសារទៀត  យកដល់មាត់អូរចូលទៅដី ។  ដល់៩៣នៅចចារ សម្ដេចក្រុងព្រះចូលស្រុកបានគេដឹកជញ្ជូនមកនៅនឹងវិញតាមព្រំដែន ។

ឈុនលី  :  ៩៣  ពូមានដឹងពេលនឹង  មានការប៉ះបោររឿងដកហូតកម្មសិទ្ធិឯកជន?

ឆាប់  :  បាទ!  ដឹងអានឹងខ្ទង់ក្នុង៨៦  ចូល៨៨ហើយចាប់ផ្ដើមយើងមានកម្មសិទ្ធិ  ដូចអ្នកខ្លះមាន ឡានអ្នកខ្លះមានអាត្រាក់  អ្នកខ្លះមានគោក្របី  នឹងថ្នាក់លើមិនដឹងមានគំនិតយ៉ាងម៉េចបាន អត់ចង់ឲ្យមានអីចឹង ។

ឈុនលី  :  ដឹងមូលហេតុអីបានអីចឹង?

ឆាប់  :  ខ្ញុំអត់សូវដឹងដែរ  ដឹងមូលហេតុអីបានគេធ្វើអីចឹង  មូលហេតុឃើញអីចឹងហើយ  ដែលនាំឲ្យ តំបន់ម៉ាឡៃនេះមានចលនាមួយប៉ះបោរ  ដូចថាមិនពេញចិត្តសម្ដែងការមិនពេញចិត្ត  ផ្ដាច់ខ្លួន ចូលរដ្ឋាភិបាលទៅ ។  មិនដឹងគោលដៅគេចង់ធ្វើម៉េច  និយាយរួមទៅយើងអត់ដឹងដែរ  យើង ថ្នាក់ក្រោមៗ ។  ហើយរងគ្រោះដូចគ្នា  មានមាស  មានខ្សែ-កតិចតួចគេប្រមូលទៅ ។

ឈុនលី  :  ចុះពូត្រូវបានគេដកហូតដែរ?

ឆាប់  :  ខ្ញុំអត់  កាលនឹងអត់ត្រូវមានគេដកហូត  ព្រោះខ្ញុំអត់ទាន់មានអីសំខាន់ដែលខ្ញុំត្រូវដក  ភាគ ច្រើនអ្នករកស៊ី៤-១០ក្នុងម៉ាស្រុកម៉ាភូមិៗ  ដូចគេមិនសូវចុះដាប់ទៅមុខ  ដូចគេពិការ  គេ មានការងារនៅក្រោយនឹងគេមានបានទៅ ។

ឈុនលី  :  ខ្ទង់៨៧  ៨៨?

ឆាប់  :  បាទ!

ឈុនលី  :  ពេលនឹងពូអត់ទាន់ទៅថៃលើទី២?

ឆាប់  :  ទៅហើយ  នឹងមកវិញហើយ ។

ឈុនលី  :  ចុះពូថាមកវិញឆ្នាំ៩៣?

ឆាប់  :  និយាយហួស  វាទៅថៃហើយមកវិញឆ្នាំ៩៣  ប្រហែលក្នុងនឹងហើយ៩៣  ៩៧  ៩៨  ចាប់ ផ្ដើម  ក្រោយអ៊ុនតាក់វៃគ្នាម៉ាសារទៀតចាប់ផ្ដើមធ្វើ ។

ឈុនលី  :  ខ្ទង់៩៣?

ឆាប់  :  អឺ!  ចាប់ពី៩៣ឡើងឡើងមករហូតផ្ដាច់ខ្លួនចន្លោះពីឆ្នាំ ។

ឈុនលី  :  ផ្ដាច់ខ្លួនឆ្នាំណា?

ឆាប់ ៖ ផ្ដាច់ខ្លួនឆ្នាំណា មើលអ៊ីនគាត់ចូលមករយៈពេល៣ឆ្នាំ ប្រហែលជា៩៤ ៩៥ ចាប់ផ្ដើមផ្ដាច់ខ្លួន។

ឈុនលី ៖ អ្នកណាគេអ្នកនាំផ្ដាច់ខ្លួន?

ឆាប់ ៖ បាទ! កាលនឹងដូចថាការពិតទៅវាមានមេនាំមែន ប៉ុន្ដែដូចថាយើងក្រោមៗដូចស៊ូទៅលែងរួច មានតែថ្ងៃយប់ដឹងតែរស់ ថ្ងៃច្បាំងគ្នាដឹងថាស្លាប់ យូរទៅគេយកកូនទៅ ដូចកូនយើងធំគេយកបញ្ជូនទៅទៀត មានអារម្មណ៍ថាបើច្បាំតែឪកុំឲ្យតដល់កូនចៅទៀត នាំគ្នារួមគំនិតគ្នាថាធ្វើម៉េចនាំគ្នាផ្ដាច់ខ្លួនចេញ។ នាំគ្នាទាក់ទងជាមួយទាហានរដ្ឋាភិបាលនៅគៀកៗចចារគ្នាទៅ

ឈុនលី ៖ អ្នកណាគេអ្នកដឹកនាំធំ?

ឆាប់ ៖ បាទ! សុខ ភាព។

ឈុនលី ៖ តែគាត់កាន់ខាងទ័ព?

ឆាប់ ៖ បាទ!

ឈុនលី ៖ ចុះប្រជាជន?

ឆាប់ ៖ កាលនឹងអត់មានប្រជាជនទេ មានគ្រួសារទ័ពទាំងអស់នារីៗស្រីៗនៅលីវធ្វើទាហានដូចគ្នា។

ឈុនលី ៖ ដឹកជញ្ជូន?

ឆាប់ ៖ ដឹកជញ្ជូនទៅ។

ឈុនលី ៖ ហ្នឹងក្រោមការគ្រប់គ្រងរបស់?

ឆាប់ ៖ បាទ! របស់សុខ ភាព។

ឈុនលី ៖ ចុះពូថាទ័ពនឹងគេមានបែងចែករយៈ ពូថា៩?

ឆាប់ ៖ បាទ! គេមានចែកជា៣កង ប៉ុន្ដែក្រោមការគ្រប់គ្រងរបស់សុខ ភាព។

ឈុនលី ៖ បានន័យថាគាត់ហើយអ្នកទាំង៣ក្រោមគាត់?

ឆាប់ ៖ បាទ! គាត់នឹងមានម៉ាចង្កោមគ្នាគាត់ផ្សេងខាងលើ ហើយគាត់រួមគ្នាចាត់តាំងកងទ័ព៣កងនឹងមាន១០៩ ១០៨ ១០៧។

ឈុនលី ៖ ១០៧នឹងអ្នកណាគេអ្នកគ្រប់គ្រង?

ឆាប់ ៖ ១០៧វ៉ាន់ សុផាត។

ឈុនលី ៖ ឥឡូវនឹងគាត់នៅរស់ទេ?

ឆាប់ ៖ ឥឡូវគាត់ទៅរៀននៅភ្នំពេញ។

ឈុនលី ៖ គាត់ធ្វើអីគេឥឡូវ?

ឆាប់ ៖ ឥឡូវគាត់កាន់ស៊ុបក្រុងប៉ៃលិន។

ឈុនលី ៖ ចុះ១០៦?

ឆាប់ ៖ ១០៦ កងចំនុះនឹងខ្ញុំ ហើយនឹងមិត្តវ៉េត អ្នកកាន់ នឹងកងដឹកជញ្ជូនទេ មិនមែនកងចំបាំងទេ ព្រោះអាជំនាន់ក្រោយអ៊ុនគាត់ ពួកយើងវាខ្វះកម្លាំងទៅៗច្បាំងទាំងអស់គ្នា ។

ឈុនលី ៖ ពួកាន់ម៉េចតែ២នាក់?

ឆាប់ ៖ វានៅសល់រស់២នាក់ៗទៀតស្លាប់ ឈ្មោះរិនក៏ស្លាប់ ឈ្មោះថេងនៅរស់ ពិការជើង គាត់ធ្វើការនៅស្រុកការិយាល័យ ។

ឈុនលី ៖ ពួហើយនឹងអ្នកណាម្នាក់?

ឆាប់ ៖ មិត្តវ៉េតប្រធាន ខ្ញុំរង ។

ឈុនលី ៖ កាលនឹងខាងដឹកជញ្ជូនសុទ្ធតែនារី?

ឆាប់ ៖ ខាងនោះដឹកជញ្ជូនមិនមែនចំពោះតែនារីទេ ដូចថាប្រធានកងទ័ពអីបាក់ស្មារតីទៅប្រយុទ្ធមិនបានអី ចូលមកនៅក្រុមដឹកជញ្ជូន ។

ឈុនលី ៖ អីចឹងកងដឹកជញ្ជូនគេហៅកងវរសេនា?

ឆាប់ ៖ អត់ទេ អានឹងគេហៅកងឯករាជ កងម៉ាវរសេនាតូចឯករាជ មិនស្មើនឹងវរសេនាធំគេមួយទេ វរៈសេនាធំគេមួយមាន៣វរសេនាតូច ។ ១០៦នឹងគេទើបចាត់តាំងដឹកជញ្ជូន បានមានអគ្គភាព១០៦ ។

ឈុនលី ៖ គេឲ្យពួកាន់ឆ្នាំណា?

ឆាប់ ៖ បាទ!ខ្ញុំកាន់ប្រហែលឆ្នាំ៨៦ ខ្ញុំចាប់ផ្តើមកាន់ យួនវ៉ៃលើកទី២ បានចាត់ផ្តើមទៅដឹកជញ្ជូន ។

ឈុនលី ៖ ហេតុអីបានគេទើបរើសពួចូល?

ឆាប់ ៖ កាលនោះខ្ញុំនៅដូចថា ពាក់កណ្តាលប្រជាជនមានគ្រួសារមានកូនចៅ គេឲ្យនៅជារបៀបពាក់កណ្តាលប្រជាជន មានត្រូវការដឹកជញ្ជូនៗ តែគេអត់ទាន់ចាត់តាំងជាអគ្គភាពទេ ។ ក្រោយមកបានដឹកជញ្ជូនឆ្ងាយៗមក គេចាត់តាំងជាអគ្គភាពដឹកជញ្ជូន ។

ឈុនលី ៖ ដូចជាតាអៀង សារីគាត់កាន់នៅតំបន់?

ឆាប់ ៖ បាទ! គាត់នៅនឹង ។

ឈុនលី ៖ អានឹងកានរបៀបម៉េច?

ឆាប់ ៖ អានឹងដូចថាគាត់នៅដឹកនាំម៉ាកន្លែងទទួលបញ្ជាពីថ្នាក់លើបញ្ជាមកនេះ ។

ឈុនលី ៖ ស្រុកម៉ាឡៃ?

ឆាប់ ៖ បាទ! គាត់ដូចថាម៉ាប៉ែកខាងត្បូងផ្លូវលេខ៥ គាត់មកកាន់ទៅប៉ៃលិនអី គាត់គ្រប់គ្រងមកលើភាព គ្រប់គ្រងមកលើ អ៊ី ឈាន តាមកងពល ។

ឈុនលី ៖ យិន យ៉ែម គាត់កាន់ខាងអី?

ឆាប់ ៖ គាត់នឹងគ្រូ គាត់ជាគ្រូបង្រៀនកូនក្មេង ។

ឈុនលី ៖ ពេលមកដល់នឹងមានសាលារៀន?

ឆាប់ ៖ មានសាលារៀន ។

ឈុនលី ៖ សាលាគេនៅណា?

ឆាប់ ៖ សាលាគេតាមម៉ាដួរយើងច្រកស្ពានចំកន្លែងគយនៅ ។

ឈុនលី ៖ អាផ្លូវទៅភូមិកណ្តាល?

ឆាប់ ៖ បាទ! អានឹងសាលារៀនមន្ទីរពេទ្យដូចភូមិវត្តចាស់ ។

ឈុនលី ៖ តែឥឡូវនឹងក្លាយជាផ្ទះប្រជាជន?

ឆាប់ ៖ បាទ! ទៅជាផ្ទះអស់ ។

ឈុនលី ៖ គាត់នឹងគ្រូធំជាងគេ?

ឆាប់ ៖ បាទ! គាត់ជាមនុស្សចាស់ទុំ កន្លែងនឹងវាគ្មានអ្នកណាសូវចេះដឹង គេតែងតាំងគាត់ធ្វើមេគ្រូនាយកសាលា ។

ឈុនលី ៖ បើចាប់ផ្តើមមានសាលារៀនឆ្នាំណា?

ឆាប់ ៖ មែនទែនទៅតាំងពី៨១ ៨២ ដែលយើងមានមូលដ្ឋានបណ្តើរៗ ពង្រីងខ្លួនបណ្តើរមានសាលា ។

ឈុនលី ៖ ដូចពូអាចបង្រៀនបាន?

ឆាប់ ៖ កាលនឹងខ្ញុំអត់មានពេលរៀនៗតែក្មេងៗ កូនចៅយើងទៅរៀនអាយុត្រូវរៀនៗ ។

ឈុនលី ៖ ដូចអង្គភាពដឹកជញ្ជូនប៉ុន្មាននាក់?

ឆាប់ ៖ កាលនឹងខ្ញុំមានកម្លាំង១០០នាក់ នឹងមិនចំពោះបានធ្វើការទាំងអស់ទេ អាខ្លះក៏ពិការ តែគេប្របាច់បញ្ចូលក្នុងអង្គភាពដឹកជញ្ជូន ។

ឈុនលី ៖ ជាមួយនារី?

ឆាប់ ៖ អឺ!

ឈុនលី ៖ ចុះឈ្មោះ អ៊ំហៀង គាត់កាន់ខាងដឹកជញ្ជូនដែរ?

ឆាប់ ៖ បាទ! ហៀង គាត់មែនទែន គាត់កាន់ខាងឃ្លាំងទេ សេដ្ឋកិច្ចឃ្លាំង ដូចថាគេដឹកសម្ភារៈមកកន្លែងឃ្លាំងស្តុបសម្រាប់ចែកចាយក្រុមគ្រួសាររបស់ទ័ព ។ ឥឡូវគាត់ធ្វើសមាគមន៍ខាងនារី ។

ឈុនលី ៖ នៅស្រុកនឹង?

ឆាប់ ៖ បាទ!

ឈុនលី ៖ ចុះពូអត់មានបន្តការងារទៀតទេ?

ឆាប់ ៖ ក្រោយមក ដល់អាយុretireនឹង និយាយរួមតាំងពីផ្តាច់ខ្លួនមក ខ្ញុំឈប់ដូចថាផ្អាកការងារ ប៉ុន្តែខ្ញុំធ្វើទាហាន គ្រាន់ទាហានគេអត់ប្រើប្រាស់ ។

ឈុនលី ៖ ដូចពូធ្លាប់កាន់អង្គភាព ពេលផ្តាច់ខ្លួនហើយគេឲ្យពូធ្វើអី?

ឆាប់ ៖ ការងារគេឲ្យខ្ញុំធ្វើវរសេនីយ៍ត្រី ។

ឈុនលី ៖ ធ្វើបានប៉ុន្មានឆ្នាំ?

ឆាប់ ៖ ខ្ញុំធ្វើតាំងពីផ្តាច់ខ្លួនមករហូត ទើបខ្ញុំពិការសុខភាព ជាប់វែតម្លៃជាប់ជាពិការឈប់ធ្វើការងារ កងពល ។

ឈុនលី ៖ កាលនឹងដូចថាអង្គភាពដឹកជញ្ជូនមានរបបគ្រប់គ្រាន់?

ឆាប់ ៖ កាលនឹងពេលដែលមានទ័ពគ្រប់គ្រង តាំងពីសំលៀកបំពាក់ខោអាវ អំបិល ប្រហុក ប៊ីចេង គេបើកឲ្យទាំងអស់ ប៉ុនបើឲ្យវាបរិបូរ វាមិនជាបរិបូរ ប៉ុនយើងអាចរស់បាន ។

ឈុនលី ៖ ដូចកាលនោះអត់ទាន់មានស្រុកអីត្រឹមត្រូវ?

ឆាប់ ៖ អត់មានទេ ដូចថាការគ្រប់គ្រងរបស់កងទ័ពបណ្តោយ របស់សុខភាពនឹង មានៗប៉ុនដូចថា ចាស់ៗជរាអី ។

ឈុនលី ៖ ពូធ្លាប់ព្ទទេ តាដូត?

ឆាប់ ៖ ធ្លាប់ព្ទ ។

ឈុនលី ៖ តាដូតនឹងខាងអី?

ឆាប់ ៖ តាដូតនឹង...ជុំវិញអំអៀង សារីនឹង ។ គាត់ខាងគេ ហើយកាលនឹងគេហៅមន្ទីរក្នុងៗ ហើយ យើងនឹងមិនសូវបានចូល ។

ឈុនលី ៖ មន្ទីរក្នុងនឹងម៉េច?

ឆាប់ ៖ មន្ទីរក្នុងនឹងដូចថាមន្ទីរកន្លែងគេរៀនសូត្រគេប្រជុំ ហើយមេធំៗអីគេស្នាក់នៅ ។

ឈុនលី ៖ កន្លែងសារតាំង?

ឆាប់ ៖ បាទ!

ឈុនលី ៖ តាដូតនឹងគាត់ធ្វើការនៅនឹង?

ឆាប់ ៖ បាទ!

ឈុនលី ៖ របៀបម៉េចទៅ ការងាររបស់គាត់?

ឆាប់ ៖ មែនទែនទៅដូចថាគាត់ជានារសា ដូចគាត់គអាជ្ញា ដូចថាខាងលើមានការងារអី ខាងលើចង់សួរ សុខ ភាព គាដូតនឹងគាត់បន្តអាជ្ញាទៅ ដូចថាយកពាក្យណែនាំទៅប្រាប់ភាព ភាពធ្វើការអី ។

ឈុនលី ៖ គាត់របៀបនារសា?

ឆាប់ ៖ បាទ! របៀបជានារសា ហើយមន្ទីរ១គាត់គ្រប់គ្រងឈ្លបការពារមន្ទីរនឹងបណ្ដោយ ។

ឈុនលី ៖ តំបន់នឹងមានមីន?

ឆាប់ ៖ បាទ! សុទ្ធតែមីន ។

ឈុនលី ៖ ពេលណាដែលចាប់ផ្ដើមមានមីនដំបូង?

ឆាប់ ៖ មីន និយាយរួមតាំងពីយើងមកដល់ តាំងពី៧៨ ៧៧ ៧៦តាមមីននៅតាមព្រំដែន មីនចំរូង ។

ឈុនលី ៖ ខាងណាអ្នកដាក់?

ឆាប់ ៖ ហ្នឹងកងទ័ពដែលនៅការពារព្រំដែន ។

ឈុនលី ៖ កងទ័ពគេមាបយូរណាស់ហើយ?

ឆាប់ ៖ បាទ! មានតាំងពីយូរណាស់ ។

ឈុនលី ៖ តាំងពីជំនាន់ពាឆ្នាំ?

ឆាប់ ៖ បាទ! ការពារព្រំដែនថៃ ។

ឈុនលី ៖ កាលនឹងតាភាពនឹងគាត់អ្នកគ្រប់គ្រង?

ឆាប់ ៖ បាទ! ខ្ញុំអត់ដឹងដល់មិនដឹងមេប៉ុន្មានជំនាន់ ជំនាន់ភាពនឹង គាត់មកក្រោយតាមខ្ញុំពួ ខ្ញុំដឹងអត់ច្បាស់ដែរ ។

ឈុនលី ៖ ដំបូងមកវាពិបាកខ្លាំង វាមានព្រៃចាញ់?

ឆាប់ ៖ បាទ! ពិបាកហើយគ្រុនចាញ់ឈឺស្លាប់ អត់ចំណីអាហារ កាលនឹងសុទ្ធតែក្បាលខ្មោចដូចថាម៉ាគ្រួសារណាដើរអត់រួចទៅលែងរួច ដេកទាល់តែងាប់ ។ វាអត់មានអ្នកណាជួយអ្នកណាបាននៅមានកម្លាំងចេះទៅពេលក្មេងអីម្ដាយស្លាប់នៅអោបម្ដាយ ។

ឈុនលី ៖ ស្លាប់ទាំងអស់គ្នា?

ឆាប់ ៖ បាទ! អត់មានអ្នកណាជួយអ្នកណាបាន កាលនឹងវាដល់កម្លាំងរៀងខ្លួន ។

ឈុនលី ៖ ពេលដែលពូចេញពីថៃមក យើងធ្វើម៉េចបានដីនៅរៀងខ្លួន?

ឆាប់ ៖ ដូចមកអង្គភាពណាគេឲ្យដាក់ត្រង់ណា គេដឹកដាក់នឹង យើងនៅត្រង់នឹង ដោះមីនពង្រីកចូក ។ កាលនឹងយើងគ្មានអីរាវទេ មានតែប៉ែតមានតែកាំបិត ។

ឈុនលី ៖ ប្រជាជនធម្មតាគាត់ដោះមីនខ្លួនឯង?

ឆាប់ ៖ បាទ!

ឈុនលី ៖ ការពិតគាត់ដូចទ័ព?

ឆាប់ ៖ ទ័ពទាំងអស់ ។

ឈុនលី ៖ អីចឹងគាត់ចេះដោះមីនដោះអី?

ឆាប់ ៖ បាទ! ដូចខ្ញុំមានប្រពន្ធ គេដឹកមកយើងគេឲ្យពេល៣-៤ថ្ងៃវាដោះ ។

ឈុនលី ៖ អត់ខ្លាច?

ឆាប់ ៖ ខ្លាចចេះខ្លាចអីខ្លះ រាវទៅជុះផាប់ៗមិនចេះតិចទេ ដែលមកពីដីថៃមកនៅនេះ ទាំងខ្ញុំទាំងអីជុះ ដូចគ្នាប៉ុនអត់អី ផាប់ទាំងប្រុស ផាប់ទាំងស្រី ។

ឈុនលី ៖ បើគិតទៅពិបាកអីជាងគេ កាលជំនាន់នឹង?

ឆាប់ ៖ ពិបាកទី១ដែលធំជាងគេ គ្រុនចាញ់ ។

ឈុនលី ៖ ប៉ុន្តែយើងមានពេទ្យគ្រប់គ្រាន់?

ឆាប់ ៖ ការស្នាក់នៅយើងអត់ទៀតទាត់ ទី២ពិបាករឿងមីន ការរស់នៅយើងចេញចូលធ្លាប់ចេញ ចូលទៅត្រង់ណាបាន ចេញទៅនឹង កន្លែងណាដែលទៅមិនបាន ។

ឈុនលី ៖ អត់ដែលហ៊ានដើរ?

ឆាប់ ៖ អត់ចេញចូលទៅបាន ប៉ុនដែលមនុស្សដែលប្រថុយរុករានធ្វើស្រែធ្វើចំការ សុទ្ធដើរមួយ ជំហានគិតមួយជំហាន ។ យើងចូកម៉ាជំហានមើលទៅមុខដើរទៅដោះ អាណាត្រូវជុះយើង ដោះ អាណាយើងកាន់បាននឹងអាចជុះក៏កាន់យកទៅគរម៉ាម្តុំទៅគរភ្លើងដុតដើរចេញ ។

ឈុនលី ៖ អានឹងតែក្តៅជុះ?

ឆាប់ ៖ បាទ! តែក្តៅវារំលាយម្ចុរជុះ ។

ឈុនលី ៖ ពេលមកពីជំរំនឹង គេហៅអីគេ ជំរំស្រះកែវ?

ឆាប់ ៖ ខ្ញុំនៅជំរំស្រះកែវ ។

ឈុនលី ៖ ខុសពី៨៥?

ឆាប់ ៖ បាទ! ខុសពី៨៥ ។

ឈុនលី ៖ ខុសគ្នាម៉េច?

ឆាប់ ៖ ស្រះកែវមានអង្គការកាទក្រហម គេដឹកយកទៅដាក់ប្រជាជនដើរមិនរួច ទៅណាមិនរួចក្រៅពី កម្លាំងទី១ដែលគេទៅវៃ ដេកនៅស្នាក់នៅផាប់តាមផ្លូវគរផាប់ គេចេះដឹកដាក់ឡានទៅ ដឹក យកដាក់ស្រះកែវ ។

ឈុនលី ៖ អានឹងខាងជំនួយកាកបាទក្រហម?

ឆាប់ ៖ បាទ!ខាងកាកបាទក្រហម ។

ឈុនលី ៖ ចុះខាងនេះ ៨៥?

ឆាប់ ៖ ហ្នឹង៨៥ជំរំយោធា ។

ឈុនលី ៖ ចុះកាលនឹងពូយោធាដែរ?

ឆាប់ ៖ បាទ! ខ្ញុំនៅអង្គភាពដឹកជញ្ជូន ។

ឈុនលី ៖ ចុះម៉េចទៅនៅស្រះកែវ?

ឆាប់ ៖ ស្រះកែវមុន កើត៨៥ ស្រះកែវកើតតាំងពី៧៩ ៨០គត់ ។

ឈុនលី ៖ អាពេលពូទៅលើកដំបូង?

ឆាប់ ៖ បាទ!

ឈុនលី ៖ ដល់ពេលទៅក្រោយនឹងទៀត?

ឆាប់ ៖ ហ្នឹង ដល់លើកក្រោយអត់ទេ លើកក្រោយទៅនៅ៨៥ ។

ឈុនលី ៖ ដល់ពេលនៅ យើងនៅចេញចូលនៅនេះ?

ឆាប់ ៖ ចេញចូលបានតែកម្លាំងប្រុសៗ ។

ឈុនលី ៖ ស្រី?

ឆាប់ ៖ ស្រីៗនៅជំរំ យើងមកប្រដាប់អាវុធមក៤-១០នាក់ ធ្វើនេះជ្រាបចូលកន្លែងណាបាន យើងចេះចូលទៅ ។

ឈុនលី ៖ គ្នាតិចម៉េច?

ឆាប់ ៖ បាទ! យើងគ្មានគ្នាច្រើនណាស់ ទៅជាក្រុមៗដូចថា ជួនកាលគេដើរ៣នាក់ ដូចថាដឹងថាយួននៅនឹងយើងលួចចេញមកពីក្រោយ បាញ់២-៣គ្រាប់ ម៉ាប័ង២ប័ង់ ហើយទៅវិញ ។

ឈុនលី ៖ បាញ់ផ្អើល?

ឆាប់ ៖ បាញ់ផ្អើល ។

ឈុនលី ៖ ចុះដូចច្បាំងគ្នាម្ដងៗរបួសច្រើនទេ?

ឆាប់ ៖ ពេលបាញ់បើយើងវៃគ្នាបានមានរបួស បើថាដូចយើងវៃដូចខ្ញុំនិយាយមិញហ្នឹងបានឃើញ ។

ឈុនលី ៖ អត់ដែលឃើញមុខគ្នាទៀត?

ឆាប់ ៖ មិនដែលឃើញមុខ ។

ឈុនលី ៖ ចុះពូដែលចូលទៅច្បាំងទៅដល់កន្លែងដែរ...?

ឆាប់ :    ខ្ញុំធ្លាប់ទៅដល់បវេលដែរ វៃតាមមុខសញ្ញា ប៉ុនវៃចេះវៃ ឧទាហរណ៍ថាពេញបាញ់ បើត្រូវមិនដឹងម៉េចស្លាប់ តែបើអត់ស្លាប់ យកមកព្យាបាល កងខ្ញុំភាគច្រើនជាទាហានកងពលទី៦ វៃគ្នា អាខ្លះត្រូនរត់មិនរួចយកមកព្យាបាលជានៅជាមួយខ្ញុំទៅ ។ នៅភាគច្រើនណាស់កងខ្ញុំសុទ្ធតែទាហាន ។

ឈុនលី : ដូចយើងបាញ់របួសខាងវៀតណាម យើងធ្វើម៉េច?

ឆាប់ :    បើយួនអត់ទេ ស៊ីសាច់ហូចឈាមគ្នា បើថាខ្មែរនឹងខ្មែរយកមក ។

ឈុនលី : ខ្មែរខាងជាមួយវៀតណាម?

ឆាប់ :    បាទ! ជាមួយវៀតណាម ។

ឈុនលី : ឲ្យតែខ្មែរយើងជួយគ្នាឯង?

ឆាប់ :    បាទ!

ឈុនលី : ចុះក្រែងយើងសត្រូវនឹងគ្នា?

ឆាប់ :    សត្រូវ ប៉ុនយើងចូលបាញ់ដឹងផុង ត្រូវណាស្លាប់ណាគេបាញ់យើងត្រូវស្លាប់ យើងបាញ់គេត្រូវស្លាប់ទៅ ។ ប៉ុនបើត្រូវរត់មិនរួចយកមក ។

ឈុនលី : យកមកអីចឹង?

ឆាប់ :    យកមកអប់រំណែនាំទៅ បើគ្នាត្រូនចាញ់ភ្លូរសារ៉ូ... ។

ឈុនលី : ចូលយជាមួយក្រុមយើងដែរ?

ឆាប់ :    បាទ! មកព្យាបាលទៅ យើងរាយការណ៍ទៅថ្នាក់លើ ដួនកាលគេឲ្យលុយឲ្យអីស្ម័គ្រចិត្តគេឲ្យទៅវិញ ។

ឈុនលី : មានលុយចាយទៀត?

ឆាប់ :    មាន ។

ឈុនលី : មានពេលណា?

ឆាប់ :    មានតាំងពី៧៩ ។

ឈុនលី : គេរកស៊ីដែរនៅនេះ?

ឆាប់ :    បាទ! គេរកឆ្លាតពេលកងទ័ពនៅទំនេរ គេដុតធ្យូត គេអារឈើកាប់ឬស្សីលក់ឲ្យថៃ ។

ឈុនលី : ថ្នាក់លើអត់ថាអី?

ឆាប់ :    អានឹងលួចធ្វើដែរ ឆ្លាត ។

ឈុនលី : ចុះពូបានធ្វើអីនឹងគេ?

ឆាប់ :    ខ្ញុំកាលនោះ ខ្ញុំធ្វើដូចនឹងគេ ដុតធ្យូតដុតអីនឹងគេ ទិញកូនជ្រូកចិញ្ចឹមទៅ ។

ឈុនលី ៖ មានកូនជ្រូក ហើយបាយជ្រូកយើងមានរបបរបស់យើង?

ឆាប់ ៖ បាទ!របប កាលនោះគេបើករបរ យើងហូបមិនអស់សល់ ហើយមិនមានអ្នកណាជ្រូកចិញ្ចឹមជាច្រើន ១-២ បាយសម្លសល់ បេះត្រកួនរួមផ្សំ ។

ឈុនលី ៖ បើគិតទៅអគ្គភាពដឹកជញ្ជូន ឈ្មោះអគ្គភាពមែន ប៉ុន្តែយើងអត់នៅរួមគ្នា?

ឆាប់ ៖ យើងនៅជាភូមិ លក្ខណៈជាភូមិ ។

ឈុនលី ៖ ផ្ទះម្នាក់មួយ?

ឆាប់ ៖ បាទ! ផ្ទះម្នាក់មួយ ។

ឈុនលី ៖ មិនមែនសហករណ៍ដូចលើកមុនទេ?

ឆាប់ ៖ អត់ទេ របបយើងបើកមក ខ្ញុំបើកយកតែផ្ទះខ្ញុំទៅ អ្នកផ្សេងបើកយកទៅគេដាំស្លតាមតែគេនឹកឃើញ គេស្លអីធ្វើអី អត់មានបាយរួមបាយអីទេ ។ បើយើងទៅជាអគ្គភាពទៅមុខ គេហូបតាមក្រុម ម៉ាក្រុមមានឆ្នាំងធំមួយដាំមានអ្នកដាំបាយ មានអ្នកទៅវ៉ៃ ។

ឈុនលី ៖ ពូថាឆ្នាំ៩៣ គេរកបង្កើតសហករណ៍ គេប្រមូល?

ឆាប់ ៖ បាទ! វាចូលដល់កន្លែងនឹង ភាសាគេថាច្បាំងតកូនតចៅ ដល់បែកថ្នាក់លើគេគិតថា ព្រោះកាលនឹងមានរត់មានអីខ្លះហើយ ។ បើអ្នកខ្លះស៊ូមិនបាន មានលុយមានកាករត់ទៅ ។

ឈុនលី ៖ រត់ទៅគេអត់ចាប់?

ឆាប់ ៖ ចុះយើងលួចរត់គ្មានអ្នកណាគេដឹង បើគេដឹងគេចាប់ ។

ឈុនលី ៖ បើខាងនោះគេចាប់បាន?

ឆាប់ ៖ ខាងខ្មែរ អានឹងអត់អីគេទាក់ទងរយៈបងប្អូនមកទទួល ។

ឈុនលី ៖ និយាយទៅគេច្បាំងកាលនឹង គេចង់ឲ្យយើងចូលជាមួយគេ?

ឆាប់ ៖ បាទ! យើងខាងនេះក៏ចង់ឲ្យខាងនោះមក ខាងនោះក៏ចង់ឲ្យខាងនេះទៅ អ្នកវ៉ៃទៅដូចខ្ញុំវ៉ៃៗពេលណាអត់វ៉ៃក៏ទាក់ទងគ្នា ជួបគ្នាអង្គុយស៊ីបាយស៊ីទឹកជុំគ្នា ។ ដល់ពេលវ៉ៃរួច ដែនការគេទៅវ៉ៃកន្លែងលោកឯង ។

ឈុនលី ៖ ដូចប្រាប់ឲ្យដឹងច្បាស់?

ឆាប់ ៖ ហ្នឹងយើងប្រាប់គ្នា អាពេលគេមកវ៉ៃយើងក៏គេប្រាប់អីចឹង អានឹងខ្មែរនឹងខ្មែរ អស់យួនហើយ ។

ឈុនលី ៖ យួនដកថយចេញអស់តែម្តង ពេលណា?

ឆាប់ ៖ យួនដកប្រហែលជាឆ្នាំ៨៥ ៨៦ យួនថយលែងមានយួននៅ ។

ឈុនលី ៖ ៨៥ ៨៦?

ឆាប់ ៖ ហ្នឹង ៨៦ ៨៧ យួនដកឈប់មកច្បាំង ។

ឈុនលី ៖ កាលនឹងដូចទាហានខាងក្នុងអ្នកណាគេអ្នកគ្រប់គ្រង?

ឆាប់ ៖ ខ្ញុំដឹងថា ដូចថាយើងវៃទល់មុខកងពលណាយើងដឹងគេ បើថាក្រៅយើងអត់ទល់មុខអត់ដឹងទេ ដូចខ្ញុំអីវៃទល់មុខជាមួយកងពលលេខ៦ ខ្ញុំដឹងកងពលលេខ៦មេឈ្មោះអី ។

ឈុនលី ៖ កងពលលេខ៦នៅណា?

ឆាប់ ៖ កងពលលេខ៦នៅណាំសាម និយាយរួមគេនៅចាំពីមាត់អូរទៅដីថៃ រហូតទៅបវេល ចក្រី ហើយកងពលទី១២គេនៅតាមផ្លូវលេខ៥ទៅចេះ អានឹងយើងស្គាល់គ្នា ។

ឈុនលី ៖ បើគិតទៅពួខាងផ្លូវជាតិ៥០២ ឥឡូវនឹងនៅភូមិអីគេ?

ឆាប់ ៖ និយាយរួចមកចាប់ពី ស្គាល់កូនដីរ៍ អាផ្លូវបែកចូលមក ហ្នឹងហើយចាប់ពីនឹងមកអាផ្លូវនឹង ។

ឈុនលី ៖ ផ្លូវមកដល់នេះ មកដល់ផ្សារម៉ាឡៃ?

ឆាប់ ៖ ផ្លូវនេះទៅឆ្ងាយនឹងប៉ៃលិន ប៉ុនមិនមែននៅនឹងទេ នៅភ្នំខាងលិច.... ។

ឈុនលី ៖ ពូដឹងទេ ពេលដែលគេប្រមូលទ្រព្យសម្បត្តិ អ្នកណាគេនាំឲ្យប្រមូល?

ឆាប់ ៖ កាលនឹងសុន សេន ។

ឈុនលី ៖ វាទៅជាជម្លោះបានមានការផ្តាច់ខ្លួន?

ឆាប់ ៖ បាទ! ជម្លោះរឿងអីចឹង ។

ឈុនលី ៖ ម៉េចខ្លះ ដូចខាងនេះយើងអ្នកណាគេប្រឆាំងជាមួយគាត់?

ឆាប់ ៖ ថានេះដូចថាបើយើងស៊ូមិនបាន ទ្រាំនឹងការគៀបសង្កត់នឹងថ្នាក់លើមិនបាន យើងឆ្លាតប្រជុំគ្នាយើង ។ តែប្រជុំនឹងមិនមែនជាចំហរទេ ប្រជុំសំងាត់ជួបគ្នា៣-៤-៥នាក់ចេះពន្យល់គ្នាគ ។ ទៅបានជាកម្លាំងធំ ទម្លាក់អាវុធឈប់ច្បាំង ។

ឈុនលី ៖ ខាងយើងនេះ ពូថាប្រជុំគ្នា?

ឆាប់ ៖ បាទ!

ឈុនលី ៖ អ្នកណាគេខ្លះ?

ឆាប់ ៖ ដូចពួកខ្ញុំមេៗ ជួបគ្នាទៅ ដូចថាមុនដំបូងខ្ញុំជួបនាងឯង អប់រំគ្នាបានយល់ព្រមថាធ្វើអីចឹង យល់គ្នាបានទៅតមួយទល់មួយ ក៏បានគ្នាច្រើន បានយើងសរុបគ្នា ។ ហើយកាលនឹងសុន សេន គាត់មានរថក្រោះមានអី យើងនៅនេះអត់មាន ។

ឈុនលី ៖ សុន សេន កាលនឹងគាត់កាន់អំណាច?

ឆាប់ ៖ កាលនឹងគាត់ថ្នាក់លើ ពីលើមកដូចអ៊ំអៀង សារី ខ្សែជាមួយគាត់ថ្នាក់លើ ។

ឈុនលី ៖ តែតំបន់នេះ តាអៀង សារី គាត់អ្នកកាន់?

ឆាប់ ៖ បាទ! ហើយគាត់នឹងខាងថ្នាក់លើពីណាបញ្ជូនឲ្យមកទៀតមក ជំនួយអីចឹង ។

ឈុនលី ៖ កាលនឹងតាប៉ុលពត គាត់នៅណា?

ឆាប់ ៖ ខ្ញុំដឹងអត់ច្បាស់ទេ តែគាត់ទីតាំងគាត់ចល័តរហូត មិនដែលទាំងជួប មិនដែលទាំងឃើញគាត់ គ្រាន់ដឹងថានៅអន្លង់វែង នៅកោះកុង ដឹងៗតែយើងមិនដែលឃើញមុខទេ ។

ឈុនលី ៖ គិតទៅគាត់មេគេ តាប៉ុលពត?

ឆាប់ ៖ បាទ!

ឈុនលី ៖ ហើយបន្ទាប់ពីគាត់មក?

ឆាប់ ៖ បន្ទាប់គាត់គណៈកម្មការគាត់មានអ៊ំអៀង សារី មានសុន សេន មានតាម៉ុកមានអី ។

ឈុនលី ៖ បានន័យថាតាសុន សេននឹង គាត់ចង់ប្រមូលអីចឹងតែតាអៀង សារីប្រឆាំង?

ឆាប់ ៖ បាទ!ព្រោះអៀង សារីគាត់ដឹកនាំរបៀបក្រសួងការបរទេសនឹងដូចថាគាត់ធ្លាប់មានពិសោធន៍ជំនាន់រដ្ឋាភិបាលមុនៗ គាត់ដឹកនាំបរទេសនឹង ។ និយាយរួមវាមិនតឹងតែងពេក វាមិនធូរពេក ។ អីចឹងនៅស្រុកនេះ គេនិយមគាត់គេចូលចិត្តគាត់ ព្រោះអ្នកនៅស្រុកម៉ាឡៃ តែចេញផុតទៅតំបន់៣២ ទៅប៉ៃលិនគេហៅតែពួកសេរីទេ ពួកប៉ាវ៉ា ។ ព្រោះស្រីៗស្លៀកពាក់ខោអាវពណ៌មុនគេ ។

ឈុនលី ៖ ឆ្នាំណាចាប់ផ្ដើមស្លៀក?

ឆាប់ ៖ ឆ្នាំ៨១ ៨២ ចាប់ផ្ដើមខោអាវពណ៌អី ។

ឈុនលី ៖ អានឹងខោអាវអីយើងបានពីណាមក ជំនួយដែរ?

ឆាប់ ៖ ក្រណាត់កាកបាទក្រហមគេបើក យើងចេះយកមកកាត់ជាឯកជនស្លៀកពាក់ អ្នកណាចង់ម៉ូតអីណាអីចេះធ្វើ ។

ឈុនលី ៖ យើងប្រើម៉ូតដូចជំនាន់មុនៗដែរ?

ឆាប់ ៖ ហ្នឹងប៉ុនគ្រាន់វាមិនមានម៉ូតអីសម័យឥឡូវទេ គ្រាន់ថាវាអាចមានរៀងមានអីខ្លះ វាប្លែកពីពណ៌ខ្មៅពីមុនមក ។

ឈុនលី ៖ ពេលយើងរត់មកពីមុនខ្មៅទាំងអស់?

ឆាប់ ៖ ខ្មៅទាំងអស់ ។

ឈុនលី ៖ មុនពេលផ្ដាច់ខ្លួនបើឈ្លោះគ្នាអីចឹង សភាពការណ៍ម៉េចទៅ ប្រជាជនអី មុនពេលផ្ដាច់ខ្លួនដូចថាយើងអត់ព្រម ខាងនេះអត់ព្រម?

ឆាប់ ៖ កាលនឹងយើងចង់វៃគ្នា បើគេអត់ព្រមវៃគ្នា គេលើកទ័ពមកទប់ទល់គ្នាត្រឹមព្រំប្រទល់បឹងបេង

ឈុនលី ៖ យុំ?

ឆាប់ ៖ បាទ! ព្រំប្រទល់ កាលនឹងគេចែកជាកងពល៤៥០នឹង ចាប់ពីនិមិត្តមកទល់នឹងគេហៅ៣២ កងពល៣២នឹង ទៅព្រំប្រទល់គីឡូ៩ ។ សុន សេនមកបាញ់កាំភ្លើងធំដាក់ភ្នំដាក់អី ហើយ យើងទៅទប់ទៅ ។

ឈុនលី ៖ នៅនេះតាសុខ ភាពនឹង?

ឆាប់ ៖ បាទ! ទៅៗយើងជួបគ្នាទ័ពត្រៀមទល់មុខគ្នានឹង ហើយចេះតែទាក់ទងព្រោះមនុស្សស្គាល់ ធ្លាប់គ្នាទាំងអស់ ។ ចេះតែជួបគ្នានិយាយគ្នា ទ័ពហើយទ័ពគេយល់គ្នាទៅ គេឈប់គិតរឿង ច្បាំង ទៅផ្ទះ បានសុន សេន គេបាក់រត់ចេញពីនឹងទៅ ។

ឈុនលី ៖ ច្បាំងនឹងយូរទេ?

ឆាប់ ៖ មិនទាន់បានបាញ់គ្នាស្លាប់រស់ទេ គ្រាន់ព្រឺដាក់គ្នា ព្រោះទ័ពទល់មុខគ្នា គេក៏ស្តាប់យើងទៅ ព្រោះកម្លាំងម៉ាចំនួននៅជាប់នេះ គេស្កាត់ជាប់នៅនេះ ម៉ាកងវរៈកងពលពួកចុះមកទន្លេសាប ពួកស្រីសុបិន្ត យើងឃាត់នៅនេះទៅ យើងអប់រំយល់ គាត់ទៅដែរនឹងប៉ះបោរទប់ទល់ជា មួយគ្នា ។

ឈុនលី ៖ ពេលនឹងតាមសុន សេននឹងគាត់ចុះមកផ្ទាល់?

ឆាប់ ៖ បាទ!

ឈុនលី ៖ ចុះនៅនេះតាអៀង សារី គាត់ចុះមកដែរ?

ឆាប់ ៖ អៀង សារីអត់ទេ អៀង សារីអត់មានវត្តមាននៅនឹងទេ កាលនឹងមិនដឹងរឿងយ៉ាងម៉េច ឬគាត់ឈឺយ៉ាងម៉េច គាត់នៅថៃនឹង ។

ឈុនលី ៖ ប្រគល់ឲ្យលោក សុខ ភាព គាត់ឡើងធ្វើ?

ឆាប់ ៖ បាទ! សុខ ភាព ។

ឈុនលី ៖ បានន័យថានៅខាងនោះ តាសុន សេននឹង គាត់កាន់ទ័ពទាំងអស់នឹង?

ឆាប់ ៖ បាទ! ខាងនោះវាមានម៉ាកងពលផ្សេង ប៉ុនកាលធ្វើនឹងខាងម៉ាខ្សែនឹង សហការជាមួយប៉ៃ លិន គេកៀងមកពីនោះមកៗវិញពីនេះទៅ ។

ឈុនលី ៖ គាត់នៅកណ្តាលគេ?

ឆាប់ ៖ គាត់នៅកណ្តាល ។

ឈុនលី ៖ តំបន់អីគេ បាននៅកណ្តាល?

ឆាប់ ៖ គាត់នៅកងពល៣២០ គេហៅតំបន់៣២កាលនឹង ។

ឈុនលី ៖ នៅនេះ១០២?

ឆាប់ ៖ បាទ!១០២ ។

ឈុនលី ៖ ដល់ពេលខាងប៉ៃលិន?

ឆាប់ ៖ ប៉ៃលិនប៉ុន្មាន ១០៥ក្មេច។

ឈុនលី ៖ ចុះ៣២សំឡូតនឹង?

ឆាប់ ៖ អត់ទេ ហៅតំបន់៣២ នៅគីឡូ១៣សាស្ត្រានឹង ភ្នំ៣២គេយកលេខភ្នំ៣២ធ្វើជាលេខកងពល។

ឈុនលី ៖ ហ្នឹងនៅសាស្ត្រា?

ឆាប់ ៖ បាទ! នឹងទីតាំងភ្នំ៣២នឹង។

ឈុនលី ៖ ពេលនឹងវត្តមានរបស់តាអៀង សារីយូរទេ?

ឆាប់ ៖ កាលនឹងខ្ញុំអត់ដឹងច្បាស់ ដឹងគាត់ឈឺ គាត់នៅសម្រាកពេទ្យនៅថៃ។ ប៉ុនមានការណែនាំពីគាត់ដែរ ឯកភាពពីគាត់ដែលបានធ្វើ។

ឈុនលី ៖ បើគិតទៅតាអៀង សារី គាត់កាន់នៅនេះឆ្នាំណា?

ឆាប់ ៖ គាត់និយាយរួមទៅ៧៩មកយើងឃើញតើ។

ឈុនលី ៖ ព្រោះកាលពីមុនគាត់ធ្វើនៅខាងក្នុង ដល់ពេល៧៩គាត់ចាប់ផ្តើមកាន់នៅនេះរហូតពេលណាបានពូបានឈប់?

ឆាប់ ៖ រហូតដល់ផ្តាច់ខ្លួននឹង ផ្តាច់ខ្លួនគាត់ទៅនៅប៉ៃលិន ផ្ទះសម្បែងគាត់សព្វថ្ងៃនៅប៉ៃលិន បើម៉ាសារមុនផ្ទះគាត់នៅនេះ មុំនេះ។

ឈុនលី ៖ នៅមុំណា?

ឆាប់ ៖ នៅគេហៅមន្ទីរក្នុងនឹង។

ឈុនលី ៖ កន្លែងសារតាំងនឹង?

ឆាប់ ៖ ហ្នឹង ផ្ទះគាត់ហួសសារតាំងតិច។

ឈុនលី ៖ សារតាំងនឹងដូចជិតនៅណា?

ឆាប់ ៖ សារតាំងនៅផ្លូវច្រកមានផ្លូវបែកខាងឆ្វេងដៃ។

ឈុនលី ៖ ផ្លូវទៅខាងអូរនឹង?

ឆាប់ ៖ បាទ! តាមមាត់អូរ មិនឆ្ងាយអាពីផ្លូវបំបែកចូលទៅថៃទេ។

ឈុនលី ៖ ជិតច្រកទៅថៃនឹង?

ឆាប់ ៖ បាទ!

ឈុនលី ៖ ....របៀបដូចអាគារមួយទៀត?

ឆាប់ ៖ ហ្នឹងហើយ អាគារតូចៗកាលនឹងគេធ្វើតាំងពីឆ្នាំ៨០ប៉ុន្មានទេខ្ញុំក្មេងចាំមិនច្បាស់ គេធ្វើទទួលសារតាំងសម្ដេចសីហនុគាត់មកពីប៉េកាំង គាត់មកទទួលសារតាំងបាន២ដង ។

ឈុនលី ៖ ទទួលពីណា ទទួលសារតាំងនឹង?

ឆាប់ ៖ កាលនឹងដូចរាជទូតគេមកដាក់ទូតប្រទេសណាមិនចាំដែរ នឹងលើកទី១ឆ្នាំ៨២ ៨៣ ។

ឈុនលី ៖ កន្លែងនឹងទទួលខាងទូតរបស់បរទេសមកទទួលនឹង?

ឆាប់ ៖ បាទ!

ឈុនលី ៖ ពេលនឹងសម្ដេចសីហនុ គាត់អត់ទាន់ចូលស្រុក?

ឆាប់ ៖ នៅទេ គាត់មកទទួលសារតាំង គាត់ទៅវិញ ឆ្នាំ៨៤គាត់មកម៉ាសារទៀត បានយួនវៃម៉ាសារ គាត់ឈប់មករហូត ។

ឈុនលី ៖ សារតាំងនឹងក្រែងពេលដែលទូតគេមកពីខាងក្រៅមកទទួលហើយ គេធ្វើការនៅស្រុកយើង?

ឆាប់ ៖ បាទ! មកនឹងគ្រាន់ថាគេមកៗទំនាក់ទំនងការងារអី គេចេញទៅវិញ គេជួយជាសម្ភារៈជាអីនឹង ។

ឈុនលី ៖ កាលនឹងពូដឹងទេ ថាមានខាងណាមក?

ឆាប់ ៖ ខ្ញុំអត់ចាំច្បាស់ វាយូរពេក ហើយយើងមិនអារម្មណ៍គិតខាងអីចឹងៗ ។

ឈុនលី ៖ យើងណែនាំគេ?

ឆាប់ ៖ មិនដឹងប្រទេសណាគេមកជួយ មកសហការ ។

ឈុនលី ៖ នៅនេះកើតជាស្រុកម៉ាឡៃពេលណា?

ឆាប់ ៖ ស្រុកម៉ាឡៃនេះ ទើបប្រកាសពេលយើងផ្ដាច់ខ្លួន ប្រកាសជាស្រុក ។

ឈុនលី ៖ ឆ្នាំ៩៦?

ឆាប់ ៖ បាទ!

ឈុនលី ៖ កាលនឹងសម្ដេចហ៊ុនសែនមក?

ឆាប់ ៖ បាទ! ពេលនឹងផ្ដាច់ខ្លួនមែនទែនៗយើងឃើញមុននឹងម៉ាឆ្នាំ មិនដល់ទេគាត់មក ។

ឈុនលី ៖ ៩៥ ៩៦?

ឆាប់ ៖ បាទ!

ឈុនលី ៖ បានន័យថាមុនពេលផ្ដាច់ខ្លួននឹងមានច្បាំងគ្នាខ្លាំង?

ឆាប់ ៖ ច្បាំង ដល់ថ្នាក់សុន សេនគាត់គៀបខ្លាំងពេក ពួកខ្ញុំគាត់នៅមុខចេះបញ្ជាឲ្យឈប់ខាងនោះមកទប់ខាងនេះវិញ ។ ប៉ុនខាងនេះគេអនុគ្រោះឲ្យគេឈប់បុករុកមក ព្រោះគេដឹងថាយើងនេះមុននឹងធ្វើអីចឹង យើងបានទាក់ទងនឹងកងពល១២ ។

ឈុនលី ៖ បានន័យថាពេលនឹងច្បាំងអ្នកខាងក្នុងនឹងផង ជាមួយគ្នាឯង?

ឆាប់ ៖ បាទ! ២ផ្នែក ។

ឈុនលី ៖ និយាយទៅដូចជម្លោះផ្ទៃក្នុង?

ឆាប់ ៖ បាទ! ជម្លោះផ្ទៃក្នុង ប៉ុនយើងមានចំនុចខ្លាំងខាងម៉ាឡៃនៅខាង ប៉ៃលិននៅខាង ដល់តំបន់... នៅកណ្តាល ខាងនេះក៏មកខាងនោះក៏ទៅគាត់ទប់អត់បាន ។

ឈុនលី ៖ ទប់អត់បានធ្វើម៉េច?

ឆាប់ ៖ គាត់រត់តែគ្នាគាត់បក្សពួកកូនចៅគាត់ ទ័ពនៅតែទ័ព ។

ឈុនលី ៖ រត់ទៅណា?

ឆាប់ ៖ រត់ចូលថៃទៅ រត់ឆ្លងដែនទៅថៃ មិនដឹងជាគេដឹកទៅណាទៀត យើងអត់ដឹង ។

ឈុនលី ៖ ចុះពេលយើងផ្តាច់ខ្លួន គេមានជួបគ្នាម៉េច?

ឆាប់ ៖ ពេលផ្តាច់ខ្លួន ថ្នាក់លើគេទៅជួបគ្នាខាងកងពលខាងក្នុងចចារគ្នាត្រូវធ្វើរបៀបម៉េច គេអនុគ្រោះឲ្យយើងរបៀបម៉េច យើងតវ៉ាជាមួយគេម៉េច យើងសុំសិទ្ធិគេត្រឹមណា ត្រូវគ្នាទៅបានយើងទៅ ។

ឈុនលី ៖ ពេលនឹងតាអៀង សារីគាត់អត់មានវត្តមាន?

ឆាប់ ៖ បាទ! គាត់អត់ទាន់មកទេ ប៉ុន្តែមានការណែនាំពីគាត់ បញ្ជាឲ្យធ្វើរបៀបម៉េច ។

ឈុនលី ៖ ចុះពេលផ្តាច់ខ្លួនគាត់ធ្វើអីទៀត តាអៀង សារី?

ឆាប់ ៖ តាអៀង សារី ផ្តាច់ខ្លួនហើយ គាត់ឈប់នៅនេះទៅ គាត់ទៅនៅប៉ៃលិន ខ្ញុំក៏អត់សូវដឹងថាគាត់ធ្វើអីទៀត ។ ប៉ុនតាមខ្ញុំដឹង តាមមើលពីខាងក្រៅដូចជាមិនមានធ្វើអី ពីព្រោះរដ្ឋាភិបាលគាត់ចុះមកគ្រប់គ្រងហើយ ។ គាត់ទៅជាមនុស្សចាស់ ។

ឈុនលី ៖ ដូចអស់តំណែង?

ឆាប់ ៖ អស់តំណែង ។

ឈុនលី ៖ ចុះបន្ទាប់ពីផ្តាច់ខ្លួនហើយ ពូធ្វើអីទៀត?

ឆាប់ ៖ បន្ទាប់ពីផ្តាច់ខ្លួនមក ខ្ញុំចូលធ្វើកងពល ធ្វើទាហាន ។

ឈុនលី ៖ ពេលណាបានមានប្រជាជនថ្មីគាត់មករស់នៅ អ្នកខាងក្នុងគេមក?

ឆាប់ ៖ មានតាំងពីជំនាន់អ៊ុនគាក់ ប្រជាជនចេញចូលសួរកូនចៅ តាំងពីជំនាន់អ៊ុនគាក់ ។

ឈុនលី ៖ ចុះបងប្អូនរបស់ពូមករកនេះអត់?

ឆាប់ ៖ មកតើ ។

ឈុនលី ៖ ឆ្នាំណា?

ឆាប់ :    មកឆ្នាំ ៩៣ ៩៤ គាត់មក បងប្រុសមកពីកំពង់ចាម មករក ។

ឈុនលី : ចុះពូធ្លាប់ទៅលេងស្រុកកំណើតវិញ ពេលណា?

ឆាប់ :    ទៅធ្លាប់ទៅពេលឆ្នាំ៨០ ទៅប៉ុន្មានឆ្នាំ២០០១ ២០០២ ។

ឈុនលី : ទើបទៅ២០០២នេះ ម៉េចអីចឹងយូរម៉េច?

ឆាប់ :    ខ្ញុំទៅនឹងមិនដឹងទៅធ្វើអី ម៉ែឪស្លាប់អស់ហើយ បងប្អូន បងខ្ញុំនៅភ្នំពេញ ហើយប្អូនមួយនៅកំពង់ធំ ខ្ញុំគ្រាន់តែដើររកបងប្អូនតែប៉ុននឹង អត់សូវចាប់អារម្មណ៍ទៅធ្វើអីផង គ្រាន់រកបងប្អូនជួបជុំគ្នាទៅ ដូចអស់អារម្មណ៍ថាទៅរកអីទៀត ។

ឈុនលី : ចុះកាលនឹងម៉េចបានពូអត់ត្រឡប់ទៅនៅនឹងវិញ?

ឆាប់ :    ព្រោះអត់មានអីសង្ឃឹមថា ទៅនឹងរស់របៀបម៉េចដូចអត់សង្ឃឹម បើនៅនឹងយើងឈរនឹងរដ្ឋាភិបាលចែកដីតាមអត្តភាពទៅ ពង្រីកខ្លួននៅមានសង្ឃឹមជាងយើងទៅស្រុកដីអស់មិនដឹងណាទៅណា អត់មានបងមានប្អូន ។

ឈុនលី : ក្រោយមកខស្សាហ៍ទៅទៀត?

ឆាប់ :    បាទ! ខ្ញុំទៅត្រឹម... ខ្ញុំអត់ទៅដល់ស្រុកកំណើត ទៅត្រឹមកំពង់ចាមទៅត្រឹមបុសខ្នុរ បងប្អូនខាងយាយរស់នៅនឹងឯង ។

ឈុនលី : គាត់អ្នកស្រុកនឹង?

ឆាប់ :    គាត់នៅកំពង់សៀម ។

ឈុនលី : បើគិតទៅពូការឆ្នាំណា?

ឆាប់ :    ការនៅឆ្នាំ៧៥ ។

ឈុនលី : ពេលធ្វើកម្មករនឹង?

ឆាប់ :    បាទ!

ឈុនលី : ចុះមីងគាត់នៅខាងនឹង?

ឆាប់ :    កាលនឹងគាត់នៅនឹងដែរ នៅកាត់ដេរសំលៀកបំពាក់ឲ្យកម្មករ ។

ឈុនលី : ពេលយើងចូលទៅស្រុកដល់ដំបូង ដូចថាគេមានការភ្ញាក់ផ្អើលអ្នកជិតខាង?

ឆាប់ :    ដូចថា ។

ឈុនលី : ដូចយើងធ្លាប់នៅនេះ?

ឆាប់ :    អត់ទេ មុននឹងយើងទៅ ទាក់ទងគ្នា គេស្គាល់យើង គេមកលេងមុនយើង ។

ឈុនលី : ដូចថាយើងធ្លាប់នៅជាមួយខ្មែរក្រហមអីចឹង គេអត់ខឹងយើងទេ?

ឆាប់ ៖ បើយើងអត់ដែលធ្វើបាបអ្នកអីគេ យើងដូចថាបើថាដូចពួកឈ្លប ពួកមេឃុំអីនឹងនៅជាប់ជាមួយប្រជាជន ដូចខ្ញុំគ្មាននៅជាប់ជាមួយប្រជាជនចេញមកចេញឲ្យផុតដូចកម្មករដូចជាកងទ័ពវាដាច់ពីការគ្រប់គ្រងឃុំភូមិ ។

ឈុនលី ៖ អីចឹងគេអត់ខឹងយើង?

ឆាប់ ៖ បាទ! គេអត់ខឹង ។

ឈុនលី ៖ តែបើឈ្លបបានគេខឹង?

ឆាប់ ៖ បាទ!

ឈុនលី ៖ បើគិតទៅ ក្រោយផ្តាច់ខ្លួន មុនពេលផ្តាច់ខ្លួនដូចថាយើងទទួលរបប ហើយដល់ពេលក្រោយមកយើងរកស៊ីខ្លួនឯង ពូគិតថាមួយណាប្រសើរជាងការរស់នៅ?

ឆាប់ ៖ ខ្ញុំគិតថាបើកាលនឹងគេមិនរវល់ បើគេមិនជួយផ្គត់ផ្គង់ ក៏យើងមិនដឹងរស់របៀបម៉េច ត្រូវតែរកកន្លែងរស់ គេជួយផ្គត់ផ្គង់ទៅយើងវើពីការផ្គត់ផ្គង់របស់គេមិនរួចទេ ត្រូវបម្រើតាមនយោបាយរបស់ថ្នាក់លើចឹងទៅ ។ ហើយដល់ឥឡូវមកផ្តាច់ខ្លួនហើយ និយាយរួមក្នុងចិត្តនឹងពេញចិត្តនឹងការរកស៊ីធ្វើស្រែធ្វើចំការតាមកម្លាំងកាយចិត្តរបស់ខ្លួន ។

ឈុនលី ៖ ទោះបីមិនមានហូបចុកក៏អត់ស្រួល?

ឆាប់ ៖ បាទៗ អត់មានគិតថាវាចេះពីមុនធ្លាប់ចេះ ឥឡូវធ្លាប់ចេះ ពេញចិត្តនឹងការរកស៊ីតែម្តងព្រោះយើងក៏មិនដឹងសង្ឃឹមស្អីរបៀបម៉េចទៀត បើមិនបញ្ចេញកម្លាំងគិត...បើមិនមានបានដល់ថ្នាក់នឹង ។

ឈុនលី ៖ ពូចាប់ចំការចាប់អី ពេលណាបានមានចំការ?

ឆាប់ ៖ បាទ! តាំងពីយើងចូលពីថៃលើកទី២ ចាប់ផ្តើមកាប់ ៩៣ ៩០អី ។

ឈុនលី ៖ ចឹងអ្នកណាចាប់បានប៉ុណ្ណា យកប៉ុននឹង?

ឆាប់ ៖ បាទ! អ្នកណាចាប់បានអ្នកណា មានលទ្ធភាពអ្នកណាទំនេរច្រើន គេកាប់បានច្រើន អ្នកណាមានលុយជួលគេខ្លះទៅបានច្រើន អ្នកអត់បានតិច ។

ឈុនលី ៖ ចុះពូចាប់បានចំការធំ?

ឆាប់ ៖ ចាប់បានច្រើន ប៉ុនកាប់មិនបានច្រើន កាប់បានតិច ។

ឈុនលី ៖ ចាប់បានច្រើន ប្តកាប់បានតិច?

ឆាប់ ៖ ប៉ុនក្រោយមកខ្ញុំមានលុយកាត់ខ្លះទៅខ្ញុំចេះទិញពង្រីកទៅណា ។

ឈុនលី ៖ ឥឡូវចំការពូនៅណា?

ឆាប់ ៖ ខ្ញុំនៅម៉ាជួរក្បែរភ្នំ ។

ឈុនលី ៖ ភ្នំអីគេ?

ឆាប់ ៖ ភ្នំរាំង ។

ឈុនលី ៖ ដាំអីគេខ្លះ?

ឆាប់ ៖ ខ្ញុំដាំដំឡូង ដាំពោត ដាំសណ្ដែក ។

ឈុនលី ៖ ដីធំ?

ឆាប់ ៖ ដីខ្ញុំ ដីចំការមានប្រហែល១០ហិចតា វា៦០រ៉ៃ ។

ឈុនលី ៖ ហើយឆ្នាំនឹងម៉េចដែរ?

ឆាប់ ៖ ឆ្នាំនឹងអត់កើតទេ និយាយរួមចំការខូច២ឆ្នាំ ។

ឈុនលី ៖ រត់មកដំបូង ឬក៏រូបថតពីមុន អាចថាពីជំនាន់៣ឆ្នាំក៏បាន ឬមួយក៏?

ឆាប់ ៖ ពីជំនាន់៣ឆ្នាំអត់មាន ។

ឈុនលី ៖ ក្រោយមកទៀត?

ឆាប់ ៖ ក្រោយមាន ។

ឈុនលី ៖ មានខ្ទង់ឆ្នាំណា?

ឆាប់ ៖ មានប្រហែលជាខ្ទង់សម័យ៨៣ ៨៤ ។

ឈុនលី ៖ ខ្ញុំអាចសុំScanរូបនឹងបាន ។

ឆាប់ ៖ ធា មើលរូបថតដែលពុកគិច អាសៀវភៅរូបថតដែលពុកថតជារូបភាពកង់ទ័ព ។

ឈុនលី ៖ ពួកខ្ញុំយកទៅធ្វើនឹងសៀវភៅដូចរបៀបចឹង អានេះជាភាសាអង់គ្លេស សៀវភៅនឹងធ្លាប់ធ្វើពីមុនមក ប៉ុន្ដែយើងធ្វើសម្រាប់ប្រជាជនទូទៅ មានគ្រប់ខេត្ត ប៉ុន្ដែលើនេះពួកខ្ញុំចង់ធ្វើទាក់ទងនឹងស្រុកម៉ាឡៃ ដោយសារតែខ្ញុំឮថាវាជិតអភិវឌ្ឍ លំនាំនេះធ្វើដូចចឹង យើងមានសាច់រឿងដូចខ្ញុំសម្ភាសន៍ពូ ហើយបន្ទាប់មកមានរូបភាពរូបថតដែលពូនៅសល់ចាស់ៗយកមកដាក់ដូចគេចឹង ។

ឆាប់ ៖ ពីជំនាន់នោះខ្ញុំគ្មាន និយាយរួមមិនបានថត មិនសូវចាប់អារម្មណ៍ ។

ឈុនលី ៖ ចុះរូបថតនឹង?

ឆាប់ ៖ កាលនឹងដូចអង្គភាពមួយៗ គេឲ្យមានអាប្រិយ៍សម្រាប់ថតរូបភាពពេលដែលវៃគ្នា យើងចេះតែថតទៅ ។

ឈុនលី ៖ ចុះមានរូបថតមានកាំភ្លើងមានអី?

ឆាប់ ៖ មាន ។

ឈុនលី ៖ ច្រើនទេ?

ឆាប់ ៖ ចាំមើលកូនរក បាត់ទៅណាទៅណៃអស់ ។ ទៅប្រជុំទៅអីខ្ញុំទៅ ទៅធ្វើការងាររយោធាអត់ទេ

ឈុនលី ៖ ពេលពូចូលធ្វើការនៅណា កងពល កន្លែងណា?

ឆាប់ ៖ ហ្នឹង ពេលដែលយើងផ្តាច់ខ្លួនហើយចូលនេះនឹង កងពលមុនដំបូងកងពល២១ ។

ឈុនលី ៖ ស្រុក?

ឆាប់ ៖ ស្រុកម៉ាឡៃនឹងម៉ង ដូចថាមានម៉ាស្រុកនឹងយើងនៅស្រុកនឹង ដល់ក្រោយមកគេប្រឫបាច់ចូលទៅពកងពលធ្វើម៉ាកងពលនៅជប់ទីតាំងនៅទំនប់... ។

ឈុនលី ៖ ដល់សព្វថ្ងៃនឹង?

ឆាប់ ៖ អឺ!

ឈុនលី ៖ អានឹងលេខប៉ុន្មានកងពល?

ឆាប់ ៖ កងពល៥១ ។

ឈុនលី ៖ ចុះកងពល៤៥០របស់លោកសុខ ភាព កាលពីមុន?

ឆាប់ ៖ ហ្នឹងមុន២១ទៀត ។

ឈុនលី ៖ គេរំលាយ?

ឆាប់ ៖ បាទ! វាផ្តាច់ខ្លួនគេឈប់ប្រើអានឹង គេប្រើលេខ២១ កងពល២១ ។

ឈុនលី ៖ ហើយកន្លែងពូធ្វើការនឹងនៅ?

ឆាប់ ៖ នៅកងពល២១ទៀត ក្រោយមកគេប្រឫបាច់កងពល២១ ១២ ហើយលេខ៧ចូលគ្នាពកងពលធ្វើម៉ាកងពល ទីតាំងវាទៅធ្វើនៅព្រះនេត្រព្រះ ។

ឈុនលី ៖ ហើយអ្នកណាគេគ្រប់គ្រង?

ឆាប់ ៖ សូ ចាន់ហេង ។

ឈុនលី ៖ គាត់ត្រូវជាម៉េចជាមួយលោកសុខ ភាពដែរ?

ឆាប់ ៖ ទេ! គាត់មិនត្រូវជាម៉េចទេ ពីមុនគាត់ថ្នាក់លើ ខាងនោះរដ្ឋាភិបាល ខាងនេះខ្មែរក្រហម គេប្រឫបាច់ចូល ។

ឈុនលី ៖ គេដូរគ្នា?

ឆាប់ ៖ ហ្នឹង គេប្រឫបាច់ចូលគេយកពកងពល យក២១ បូកជាមួយកងពលទី៧ អឺ!១២ប្រឡំ ទៅបូកជាមួយកងពលលេខ៧មួយទៀត គេធ្វើម៉ាកងពល ។

ឈុនលី ៖ រហូតដល់ឥឡូវគាត់ សូ ចាន់ហេង គាត់នៅគ្រប់គ្រងនឹង?

ឆាប់ ៖ ហ្នឹងគាត់នៅកាន់កងពលនឹង ។

ឈុនលី ៖ ហើយលោកសុខ ភាព គាត់ឡើងធំ?

ឆាប់ ៖ ភាព គាត់ឡើងទៅលើទៀត ។

ឈុនលី ៖ គាត់ឡើងពេលផ្កាច់ខ្ទួន?

ឆាប់ ៖ បាទ! គាត់ទៅខាងទីប្រឹក្សាសម្តេច ។

ឈុនលី ៖ គាត់ខស្សរាប់មកលេង?

ឆាប់ ៖ មក ។

ឈុនលី ៖ មកប្រជុំនៅកន្លែង?

ឆាប់ ៖ អត់ទេ គាត់អត់ដែលប្រជុំទេ គាត់មកជាលក្ខណៈគ្រួសារ មកធ្វើបុណ្យធ្វើទាន អញ្ជើញគាត់មកៗ ។

ឈុនលី ៖ បុណ្យទាននៅវត្ត?

ឆាប់ ៖ បាទ!

ឈុនលី ៖ វត្តណា គាត់ខស្សរាប់មក?

ឆាប់ ៖ មកវត្តម៉ាខ្មែ និយាយរួមឲ្យវត្តណាគេអញ្ជើញគាត់ ការកូនការអី ។

ឈុនលី ៖ ខ្ញុំឃើញកន្លែងរូបរទេះគោនៅផ្សារ ខ្ញុំឃើញដាក់ឈ្មោះគាត់?

ឆាប់ ៖ អានឹងគេធ្វើជំនាន់ផ្កាច់ខ្ទួន ។

ឈុនលី ៖ ៩៦?

ឆាប់ ៖ បាទ!

ឈុនលី ៖ អានឹងតំណាងអីគេ?

ឆាប់ ៖ ដូចថាជំនាន់នឹងគេដករទេះគោ គេសម្រេចចិត្តយករទេះគោនឹងធ្វើជាវង្វង់មូល ។ ហើយដូចនៅខាង៣២គេដាក់វង្វង់មូលដាក់អាត្រាក់ទៅ ដកអាត្រាក់ ។

ឈុនលី ៖ គេចែកគ្នាដាក់ចឹង?

ឆាប់ ៖ អឺ!

ឈុនលី ៖ តំណាងថាពេលនឹងគេដក ។ ចឹងខ្ញុំអរគុណច្រើនហើយ

«ចប់»